វេទិកាអនាគត
Future Forum

គោរពជូន សហការី សមាជិកគណៈកម្មការនាយកប្រតិបត្តិ និងដៃគូសហប្រតិបត្តិការ

យើងមានសេចក្តីសោមនស្សជាខ្លាំង ក្នុងការប្រកាសលោកសាស្ត្រាចារ្យ David Chandler ជាប្រធានគណៈកម្មការនាយកប្រតិបត្តិផ្នែកសិក្សាធិការនៃអង្គការវេទិកាអនាគត។

លោកបណ្ឌិត Chandler ត្រូវបានចាត់ទុកជាបញ្ញវន្តបច្ចឹមប្រទេសដ៏ល្បីល្បាញម្នាក់លើប្រវត្តិសាស្ត្រកម្ពុជាសហសម័យ ដោយបានបោះពុម្ពសៀវភៅ៥ក្បាលអំពីប្រទេសនេះ។ ស្នាដៃដ៏លិចធ្លោរបស់លោកនៅឆ្នាំ១៩៨៣ «សៀវភៅប្រវត្តិសាស្ត្រកម្ពុជា» ទំនងជាស្នាដៃដ៏ល្បីល្បាញបំផុតមួយ និងត្រូវបានចាត់ទុកជាការរួមចំណែកដ៏សំខាន់ចំពោះប្រវត្តិសាស្ត្រកម្ពុជា។ កាលពីខែមេសាកន្លងទៅ លោកបណ្ឌិតត្រូវបានប្រគល់ជូនពានរង្វាន់ឆ្នើមសម្រាប់ការចូលរួមចំណែកក្នុងការសិក្សាអំពីអាស៊ី (Award for Distinguished Contributions to Asian Studies) ដោយសមាគមសិក្សាអំពីអាស៊ី (Association for Asian Studies) សម្រាប់ការចូលរួមចំណែកដ៏មានអត្ថប្រយោជន៍របស់លោក ក្នុងការសិក្សាអំពីប្រវត្តិសាស្ត្រ នយោបាយ និងវប្បធម៌កម្ពុជា។

បន្ទាប់ពីបានបញ្ចប់ការសិក្សានៅសកលវិទ្យាល័យ Harvard លោក David បានចាប់ផ្តើមមានទំនាក់ទំនងការងារផ្លូវការជាមួយកម្ពុជា ដោយបម្រើការជាមន្ត្រីកិច្ចការបរទេសអាមេរិក ប្រចាំស្ថានទូតសហរដ្ឋអាមេរិកក្នុងរាជធានីភ្នំពេញពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦២។ ការងារបន្តបន្ទាប់ក្នុងវិស័យការទូតនិងសិក្សាធិការរបស់លោករួមមាន ជាទីប្រឹក្សាជាន់ខ្ពស់របស់ទីភ្នាក់ងារជំនួយនិងទំនាក់ទំនងអន្តរជាតិរបស់អាមេរិក (USAID) មូលនិធិអាស៊ី មជ្ឈមណ្ឌលខេមរៈសិក្សា និងអង្គការសង្គមស៊ីវិលផ្សេងទៀត ដូចជាអង្គការនិទណ្ឌភាពអន្តរជាតិ ក្នុងការសិក្សា និងបេសកកម្មស្វែងរកការពិតនៅកម្ពុជា។ កិច្ចការទាំងនោះ គឺបន្ថែមពីលើអាជីពបង្រៀនរបស់លោកនៅសកលវិទ្យាល័យ Monash, សកលវិទ្យាល័យ Cornell, សកលវិទ្យាល័យ Georgetown និង សកលវិទ្យាល័យ Michigan និង Wisconsin។

វេទិកាអនាគត ចាត់ទុកបទពិសោធន៍របស់លោក David ខាងលើ រួមជាមួយនឹងចំណង់ចំនួលចិត្ត និងគោលគំនិតរបស់លោកក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ជាសម្បត្តិដ៏មានតម្លៃបំផុតសម្រាប់កម្មវិធីនិងបេសកកម្មរបស់យើង៕

ដោយក្ដីគោរពរាប់អាន

អ៊ូ វីរៈ

ស្ថាបនិក និងប្រធាន

- សម្រាប់ជីវប្រវត្តិលម្អិតរបស់លោក https://www.futureforum.asia/our-team/
- សម្រាប់ព័ត៌មានបន្ថែម៖ ouvirak@gmail.com